សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង
សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន
"គម្រោងបង្កើនសមត្ថភាពក្រុមបោសសំអាតកាកសំណល់ជាតិផ្ទុះពីសង្គ្រាម"
១១ ធ្នូ ២០១៤

- **សូមគោរព ឯកឧត្តម អ៊ុំ ភូមិរ៉ូ អគ្គនាយករងអង្គការ CMAC!**
- **សូមគោរពលោកស្រី ហ្វុយិកាមិ ហិរុមិ ប្រធានតំណាងអង្គការ JMASប្រចាំកម្ពុជា!**
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនគឺ "គម្រោងបង្កើនសមត្ថភាពក្រុមបោសសំអាតកាកសំណល់ជាតិផ្ទុះពីសង្គ្រាម" ។

ដូចដែលយើងទាំងអស់គ្នាបានដឹងហើយថា កម្ពុជាមានកាកសំណល់ជាតិផ្ទុះរាប់លានដែលបានបន្សល់ពីសង្គ្រាម។ វត្តមាននៃគ្រាប់មីន និងយុទ្ធភ័ណមិនទាន់ផ្ទុះគឺជាឧបសគ្គដ៏ធំមួយសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា ហើយការបោសសំអាតកាកសំណល់ជាតិផ្ទុះនេះគឺជាជំហ៊ានមិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេដ្ឋកិច្ចក៏ដូចជាវិស័យកសិកម្មផងដែរ។

ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរយៈពេលវែង ចំនួនជនរងគ្រោះដែលបណ្តាលមកពីគ្រាប់មីននិងយុទ្ធភ័ណមិនទាន់ផ្ទុះបាននិងកំពុងថយចុះ។ រដ្ឋាភិបាលជប៉ុន បាននិងកំពុងបន្តឧបត្ថម្ភគាំទ្រដល់កិច្ចខិតខំប្រឹងប្រែង របស់កម្ពុជាតាមរយៈជំនួយឥតសំណង ក៏ដូចជាកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស។ យ៉ាងណាមិញ នៅតែមានជនរងគ្រោះដោយសារគ្រាប់មីននិងយុទ្ធភ័ណមិនទាន់ផ្ទុះចំនួន១១១នាក់ក្នុងឆ្នាំ២០១៣ ដូច្នេះបានជាយើងចង់បង្កើតប្រព័ន្ធមួយសម្រាប់ពង្រីកឥទ្ធិពលនៃការផ្ទេរបច្ចេកទេសទៅកាន់អង្គការCMAC ដែលជាអង្គការស្នូលនៃការសំអាតគ្រាប់មីន និងយុទ្ធភ័ណមិនទាន់ផ្ទុះនៅក្នុងប្រទេសកម្ពុជា។

ដោយសារតែមានស្ថានភាពបែបនេះ ទើបអង្គការJMASបាននិងកំពុងអនុវត្តគម្រោងក្នុងខេត្តចំនួនបីតាំងពីឆ្នាំ២០០២ តាមរយៈជំនួយឧបត្ថម្ភថវិការរបស់ជប៉ុនសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ដោយសហការជាមួយCMAC។ រយៈពេល១០ឆ្នាំកន្លងមកនេះ អង្គការJMASបានទទួលជោគជ័យក្នុងសកម្មភាពបោសសម្អាតមីន និងយុទ្ធភ័ណមិនទាន់ផ្ទុះ ក៏ដូចជាការផ្ទេរបច្ចេកទេសជាច្រើនទៅដល់CMAC ដែលជាការចូលរួមចំណែកដ៏ធំធេងក្នុងការកសាងសន្តិភាព និងការអភិវឌ្ឍក្នុងប្រទេសកម្ពុជា។

រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាប្រមាណ ៥០លានយ៉េនជូនដល់គម្រោងរបស់អង្គការJMAS។ យើងបានដឹងថា អង្គការJMAS នឹងអនុវត្តគម្រោងបោសសំអាតមីន និងយុទ្ធភ័ណមិនទាន់ផ្ទុះក្នុងបណ្តាខេត្តនានា និងរៀបចំកម្មវិធីអប់រំកសាងសមត្ថភាព ក្នុងគោលបំណងដើម្បីបង្កើនប្រសិទ្ធិភាពការងាររបស់ក្រុមបោសសំអាតកាកសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលរួមមានគ្រូណែនាំផងដែរ។ យើងសង្ឃឹមថាគម្រោងនេះនឹងអាចបង្កើនល្បឿននៃការសម្រេចតាមផែនការរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបោសសំអាតយុទ្ធភ័ណមិនទាន់ផ្ទុះត្រឹមឆ្នាំ២០១៩។

លើសពីនេះទៀត ចាប់តាំងពីករណីផ្ទុះកាកសំណល់ជាតិផ្ទុះពីសង្គ្រាមកាន់តែច្រើនត្រូវបានគេរាយការណ៍នៅពេលដែល ការអភិវឌ្ឍដីធ្លីក្នុងប្រទេសកម្ពុជាមានការរីកចំរើន ពួកគេនឹងផ្ទេរបច្ចេកទេសសម្រាប់ស្វែងរកយុទ្ធភ័ណមិនទាន់ផ្ទុះដែលកប់នៅក្នុងដីជ្រៅជាងមុន។ យើងរំពឹងថាគម្រោងនេះ នឹងអាចបញ្ចៀសពីគ្រោះថ្នាក់កើតឡើងជាយថាហេតុក្នុងអំឡុងពេលការសាងសង់ដែលត្រូវបានប្រើដោយម៉ាស៊ីនសំណង់ធុនធ្ងន់ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។

ខ្ញុំសង្ឃឹមថា គម្រោងនេះនឹងអាចធ្វើអោយប្រសើរឡើង នូវការអភិវឌ្ឍសមត្ថភាពរបស់CMACបន្ទាប់ពីការសំអាតយុទ្ធភ័ណមិនទាន់ផ្ទុះ ដែលធ្វើអោយប្រជាពលរដ្ឋចំនួន ១,៧៤៥,000នាក់ក្នុងសហគមន៍ រួចផុតពីផលវិបាកនៃសំណល់ជាតិផ្ទុះ ហើយរស់នៅប្រកបដោយស្ថេរភាព មានការកែលម្អបរិស្ថាន និងមានការអភិវឌ្ឍសហគមន៍អោយកាន់តែប្រសើរឡើង។

ជាចុងក្រោយនេះ ជំនួយឧបត្ថម្ភរបស់ជប៉ុនសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុនត្រូវបានផ្តល់ជូនសម្រាប់គម្រោងអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ចដែលប៉ះពាល់ផ្ទាល់ដល់ប្រជាពលរដ្ឋនៅតាមថ្នាក់មូលដ្ឋាន។ ហើយខ្ញុំសូមធ្វើការគោរពដោយស្មោះចំពោះអ្នកទាំងអស់គ្នាដែលបានរួមចំណែកក្នុងកិច្ចការបោសសំអាតមីន និងយុទ្ធភ័ណមិនទាន់ផ្ទុះ ដែលជាកិច្ចការដ៏លំបាក។ ហើយគម្រោងនេះ នឹងមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់ប្រជាជនក្នុងតំបន់ប៉ុណ្ណោះទេ ថែមទាំងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជាដែលមានរួចស្រាប់ផងដែរ។